ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងរដ្ឋប្បវេណីលេខ:១៣៥

ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

-សាលក្រមលេខ: ១៨ "ច"

ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ១៣៥ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើមចោទឈ្មោះ** [redacted] សុខនី ភេទស្រី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩២ សញ្ជាតិខ្មែរ មុខរបរ កម្មការនីរោងចក្រ ទីលំនៅបច្ចុប្បន្ន [redacted] ។

មានលោកមេធាវី [redacted] អត្តលេខ ៣២៥ និងលោកមេធាវី [redacted] អត្តលេខ ២៨២១T ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ភេទប្រុស កើតថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៨២ សញ្ជាតិខ្មែរ មុខរបរ យោធា ទីលំនៅបច្ចុប្បន្ន [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញៈ

ក.១-លែងលះពីចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ។

ក.២-សុំសិទ្ធិអំណាចមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] សុនីតា ភេទស្រី កើតថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២១ ។

ក.៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ខ-ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ហើយស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយបង្កើតបានកូនស្រីចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើមចោទ និងចុងចម្លើយចេះតែឈ្លោះប្រកែកគ្នា ដោយសារតែចុងចម្លើយចេះតែមួម៉ៅក្តៅក្រហាយនៅពេលដែលអត់មានលុយកាក់ ខ្វះទំនុកចិត្តមកលើដើមចោទ និងបានរស់នៅបែកគ្នា ដែលធ្វើឲ្យអស់មនោសញ្ចេតនា

នឹងគ្នាជាប្តីប្រពន្ធតទៅទៀត ។ ដើមចោទបានឈប់រស់ជាមួយចុងចម្លើយអស់រយៈពេលជិតមួយឆ្នាំ ហើយនៅពេលដែលដើមចោទមករស់នៅជាមួយម្តាយបង្កើតវិញ ដើមចោទបានសុំយកកូនមករស់នៅជាមួយ តែចុងចម្លើយហាមដាច់ខាតមិនឱ្យនាងខ្ញុំយកកូនមកជាមួយទេ ថែមទាំងមិនឱ្យជួបមុខកូនទៀត ។ ដោយសារតែដើមចោទមិនអាចបន្តរស់នៅជាមួយនឹងចុងចម្លើយបានទៀត ទើបដើមចោទដាក់ពាក្យបណ្តឹងលែងលះមកតុលាការតែម្តង ។

**គ-ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការកំណត់បានចំណុចវិវាទនៃរឿងក្តីមានដូចតទៅ:

គ.១-ចំណុចវិវាទ :

-តើដើមចោទមានមូលហេតុគ្រប់គ្រាន់ក្នុងការទាមទារលែងលះពីចុងចម្លើយ និងទាមទារអំណាចមេបាលើកូនដែរ ឬទេ?

**គ.២-ចំណុចគ្មានវិវាទ:** ភាគីទាំងសងខាងពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងមានកូនចំនួន ០១នាក់ ពិតមែន ។

**ឃ-សេចក្តីថ្លែងការណ៍របស់គូភាគី**

**ឃ.១-សេចក្តីថ្លែងការណ៍របស់ដើមចោទ**

-ដើមចោទឈ្មោះ [redacted] សុខនី បានធ្វើសេចក្តីថ្លែងការណ៍ថា: នាងខ្ញុំ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ហើយស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ នាងខ្ញុំ និងចុងចម្លើយបង្កើតបានកូនស្រីចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។ នាងខ្ញុំ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដីឡូតិ៍ចំនួន ០២ឡូតិ៍ ស្ថិតនៅខេត្តកំពង់ស្ពឺ ។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នាងខ្ញុំ និងចុងចម្លើយចេះតែឈ្លោះប្រកែកគ្នាស្ទើររាល់ថ្ងៃ ដោយសារតែចុងចម្លើយចេះតែមួម៉ៅក្តៅក្រហាយនៅពេលដែលអត់មានលុយកាក់ ហើយតែងតែជេរប្រមាថ និងប្រើពាក្យសំដីមើលងាយនាងខ្ញុំ មិនឱ្យតម្លៃ ខ្វះទំនុកចិត្តមកលើរូបនាងខ្ញុំ ដែលធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធតទៅទៀត ។ នាងខ្ញុំបានឈប់រស់ជាមួយចុងចម្លើយអស់រយៈពេលជិតមួយឆ្នាំ ហើយនៅពេលដែលនាងខ្ញុំមករស់នៅជាមួយម្តាយបង្កើតវិញ នាងខ្ញុំបានសុំយកកូនមករស់នៅជាមួយ តែចុងចម្លើយហាមដាច់ខាតមិនឱ្យនាងខ្ញុំយកកូនមកជាមួយទេ ថែមទាំងមិនឱ្យជួបមុខកូនទៀត ។ ទង្វើរបស់ចុងចម្លើយ គឺបានបង្ហាញឱ្យនាងខ្ញុំឃើញថា ពួកខ្ញុំទាំងពីរនាក់មិនអាចរួមរស់ជាប្តីប្រពន្ធបន្តទៅមុខទៀតបានទេ ។ ហេតុនេះហើយ ទើបនាងខ្ញុំដាក់ពាក្យបណ្តឹងមកតុលាការ និងស្នើសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់នាងខ្ញុំផង ។

ក្នុងករណីដែលចុងចម្លើយមិនព្រមប្រគល់អំណាចមេបាលើកូនឱ្យនាងខ្ញុំ គឺនាងខ្ញុំសុំទាមទារទ្រព្យសម្បត្តិរួមពីចុងចម្លើយដូចជា៖ ដីចំនួន ០២ឡូតិ៍ និងមាសចំនួន ០៥ជី (ជាចំណងដៃ) ។ ដោយឡែក ចំពោះដីអំណោយដែលឪពុកម្តាយបង្កើតរបស់នាងខ្ញុំឱ្យមកនាងខ្ញុំ និងចុងចម្លើយគឺមានដីលំនៅដ្ឋានចំនួន ០២កន្លែង មានសាងសង់ផ្ទះលើដីនេះចំនួន ០១ខ្នង និងដីស្រែចំនួន ០២កន្លែង ស្ថិតនៅភូមិសិង្ហ ឃុំសិង្ហ ស្រុកសំរោង ខេត្តតាកែវ ។

Scanned with CamScanner

មូលហេតុដែលនាងខ្ញុំចុះចេញពីផ្ទះ គឺដោយសារតែចុងចម្លើយដេញនាងខ្ញុំចេញពីផ្ទះ និងមិនឱ្យនាងខ្ញុំយកកូនមកទេ ដោយម្ដាយក្មេកជាអ្នកយកគេចមិនឱ្យនាងខ្ញុំឃើញនោះទេ ។ ក្រោយមកបានចំនួន ០២ថ្ងៃ នាងខ្ញុំក៏បានទៅរកកូន តែចុងចម្លើយជាអ្នកទាញកូនចេញពីដៃនាងខ្ញុំ ។ មួយវិញទៀតបើនាងខ្ញុំយកកូនមកតាម ក៏នាងខ្ញុំរស់នៅមិនបានសុខដែរ ដោយសារតែចុងចម្លើយចេះតែរករឿងនាងខ្ញុំរហូត ។ មកដល់ពេលនេះនាងខ្ញុំសូមក៏សិទ្ធិទៅជួបមុខកូន ព្រោះថារាល់ថ្ងៃគឺចុងចម្លើយ មិនដែលឱ្យនាងខ្ញុំទៅជួបកូននោះទេ ។ នាងខ្ញុំដាច់ខាតមិនអាចរស់នៅជាប្ដីប្រពន្ធនឹងគ្នាតទៅទៀតទេ ព្រោះនាងខ្ញុំអស់ជំនឿលើគាត់ហើយ ព្រោះចុងចម្លើយមិនដែលខ្វល់ជាមួយនាងខ្ញុំក្នុងនាមជាប្រពន្ធនោះទេ ព្រោះគ្រប់រឿងរបស់គាត់ទាំងអស់ គឺគាត់លាក់បាំងនឹងនាងខ្ញុំទាំងអស់ មួយវិញទៀតគ្រប់ពេលដែលកូនឈឺគឺគាត់តែងតែខឹងរករឿងនាងខ្ញុំ ដោយសារគាត់ចង់ឱ្យនាងខ្ញុំតមគ្រប់យ៉ាង ប៉ុន្តែនាងខ្ញុំមិនអាចតមតាមគាត់នោះទេ ព្រោះថានាងខ្ញុំក៏ត្រូវហូបអីដែលមានអត្ថប្រយោជន៍ដើម្បីមានទឹកដោះគ្រប់គ្រាន់សម្រាប់ឱ្យកូនបៅ ។ ចំពោះការចិញ្ចឹមមើលថែកូន នាងខ្ញុំក៏មានលទ្ធភាពគ្រប់គ្រាន់ដែរ ព្រោះថាកន្លងមកនាងខ្ញុំ ក៏ធ្លាប់ចិញ្ចឹងកូនអស់រយៈ ពេលជាង២ឆ្នាំមកហើយដែរ ហើយនាងខ្ញុំក៏មានការងារ មានប្រាក់ខែសម្រាប់ចិញ្ចឹមបីបាច់កូន ឱ្យកូនរៀនបានខ្ពស់ និងអាចមានផ្ទះឱ្យកូនរស់នៅ នៅពេលដែលកូនធំ ។ ហើយមួយវិញទៀត ក្នុងនាមនាងខ្ញុំជាម្ដាយអាចផ្ដល់ក្ដីស្រឡាញ់ឱ្យកូនមានការកក់ក្ដៅជាងនៅជាមួយឪពុក ។

-លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្ញុំបាទសូមស្នើសុំឱ្យតុលាការសម្រេចលែងលះឱ្យកូនក្ដីរបស់ខ្ញុំ ក៏ដូចជាសុំឱ្យកូនក្ដីរបស់ខ្ញុំបាទមានសិទ្ធិអំណាចមេបាលើកូន ដោយហេតុថា: ក្នុងនាមកូនក្ដីរបស់ខ្ញុំបាទជាម្ដាយ គឺអាចផ្ដល់នូវក្ដីស្រឡាញ់គ្រប់គ្រាន់ដល់កូន អាចឱ្យកូនមានភាពកក់ក្ដៅ និងអាចទូន្មានកូនឲ្យក្លាយជាមនុស្សល្អ ជៀសផុតពីរឿងពាលាអាវ៉ាសែ ហើយកូនក្ដីរបស់ ខ្ញុំបាទក៏មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន មួយវិញទៀតកូនរបស់កូនក្ដីរបស់ខ្ញុំបាទនៅតូច ត្រូវការបៅទឹកដោះម្ដាយ ព្រោះទឹងដោះម្ដាយមានសារជាតិគ្រប់គ្រាន់ ល្អប្រសើជាងបៅទឹកដោះគោ ។

### ឃ.២-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] ស៊ីដេត បានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្ញុំបាទពិតជាបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ជាមួយនឹងដើមចោទឈ្មោះ [redacted] សុខនី ព្រមទាំងមានកូនជាមួយគ្នាចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា ភេទស្រី កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ពិតមែន ។ ក្នុងការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ តែងតែមានជម្លោះពាក្យសម្ដីជាមួយគ្នាបន្តិចបន្តួចខានមិនបានទេ ខ្ញុំបាទគ្រាន់តែណែនាំ ដោយមិនបានជេរស្ដី និងប្រើពាក្យមើលងាយដូចការថ្លែងការណ៍របស់ដើមចោទនោះទេ ។ ចំពោះការលែងលះគឺខ្ញុំបាទមិនចង់នោះទេ តែបើគាត់មានមូលហេតុគ្រប់គ្រាន់ក្នុងការលែងលះ ខ្ញុំបាទសូមឱ្យគាត់បង្ហាញឱ្យច្បាស់លាស់ ហើយបើមានមូលហេតុគ្រប់គ្រាន់ទើបខ្ញុំព្រមលែង ពីព្រោះថាខ្ញុំបាទមិនចង់ឱ្យរស់នៅកំព្រាឪពុកម្ដាយនោះទេ ។ ដោយឡែកចំពោះការទាមទារសិទ្ធិអំណាចមេបាលើកូន គឺខ្ញុំបាទសូមបដិសេធមិនព្រមតាមការទាមទាររបស់ដើមចោទនោះទេ ព្រោះថាសព្វថ្ងៃកូនគឺរស់នៅជាមួយខ្ញុំបាទ និងម្ដាយ ដែលមានការចិញ្ចឹមបីបាច់មើលថែរបានយ៉ាងល្អ ណាមួយខ្ញុំបាទមានការងារច្បាស់លាស់ ជាមន្ត្រីរាជការម្នាក់ដែលមានប្រាក់ខែគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់

ឲ្យលើដល់កូនផងដែរ  មួយវិញទៀតកូនគឺរស់នៅជាមួយខ្ញុំនៅភ្នំពេញស្រាប់  ដែលរួមមានទាំងសាលារៀន មន្ទីរពេទ្យ ក៏ដូចជាអ្វីៗផ្សេងទៀតជាច្រើន ដែលធ្វើឱ្យមានភាពងាយស្រួលក្នុងការរស់នៅ ហើយអ្វីដែលសំខាន់ គឺកូនរស់ស្ថិតក្រោមការមើលថែរបស់ខ្ញុំបាទផ្ទាល់ ពេលដែលខ្ញុំបាទទៅធ្វើការកូននៅជាមួយម្តាយខ្ញុំ០១នាក់ ប្អូន០១នាក់ និងក្មួយចំនួន០៤នាក់ទៀត ជាអ្នកមើលថែរ ហើយគាត់នៅលីវទាំងអស់ ។ មួយវិញទៀតចុងចម្លើយបានចុះចេញពីកូនតាំងពីកូននៅតូចមកម្លេះ ចាប់តាំងពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ម៉ោង១០ និង៥៥នាទីព្រឹក រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ នេះ ជិតមួយឆ្នាំហើយ ។ ត្រង់ចំណុចនេះគឺខ្ញុំបាទមិនអាចយល់ព្រមតាមការទាមទារដាច់ខាត ។ ក្នុងចំណងអាពាហ៍ពិពាហ៍ ខ្ញុំបាទ និងដើមចោទបានបង់រំលួសដីចំនួន ០២ឡូតិ៍ បង់ដាច់មួយនៅសល់មួយទៀត និងមានអំណោយពីម្តាយក្មេកជាដីស្រែ និងផ្ទះប្រហែលជា ០៣កន្លែង ស្ថិតនៅភូមិសិង្ហ ឃុំសិង្ហ ស្រុកសំរោង ខេត្តតាកែវ ។ ហើយខ្ញុំបាទសូម បដិសេធចោលរាល់ពាក្យសម្តីរបស់ដើមចោទ ដែលចោទប្រកាន់ខ្ញុំបាទគ្មានមូលដ្ឋាន និងគ្មានភស្តុតាងច្បាស់លាស់ ។

ខ្ញុំបាទសូមបន្ថែមភស្តុតាងមួយចំនួន ដែលបញ្ជាក់ពីប្រាក់ខែរបស់ខ្ញុំបាទជាមន្ត្រីរាជការ ព្រមទាំងប្រាក់ឧបត្ថមរបស់លោកឧកញ្ញា [redacted] សុជាតិ ចនួន ៦០០$ ក្នុងមួយខែ ក៏ដូចជាពាក្យបណ្តឹងដែលខ្ញុំបាទ បានប្តឹងទៅលើដើមចោទ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នៅពេលដែលខ្ញុំបាទរៀបការជាមួយដើមចោទ  គឺគាត់ជាមេម៉ាយកូនមួយ  ហើយកូននោះស្ថិតក្នុងបន្ទុករបស់ដើមចោទស្រាប់  ហើយកូនឈ្មោះ [redacted] សុខនីតា គឺជាកូនតែម្នាក់គត់របស់ខ្ញុំ ហេតុដូច្នេះ ខ្ញុំបាទមិនអាចឲ្យកូនទៅរស់នៅជាមួយគាត់បាននោះទេ ។

ង.ឯកសារភស្តុតាងដែលដើមចោទដាក់ឲ្យតុលាការពិនិត្យ៖

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ៖៤៩  នៃសៀវភៅអាពាហ៍ពិពាហ៍លេខ៖០១/២០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ ។

-សេចក្តីចម្លងសំបុត្រកំណើតលេខ៖១២៩ នៃសៀវភៅកំណើតលេខ៖០៤/២០២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ។

-កិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ។

ច.ឯកសារភស្តុតាងដែលចុងចម្លើយដាក់ឲ្យតុលាការពិនិត្យ៖

-សៀវភៅគ្រួសារលេខ៖០០០១០៩ ស.រ ។

-សៀវភៅស្នាក់នៅលេខ៖ស.០០០៨៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖០១១២៦៥៧២២ ។

-អត្តសញ្ញាណប័ណ្ណនាយទាហាន ។

-ប័ណ្ណបើកប្រាក់បៀវត្ស ។

-ពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ។

-កិច្ចសន្យាការងារមានថិរវេលា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ។

-រូបថត (ចំនួន២៥សន្លឹក) ។

Scanned with CamScanner

## សំអាងហេតុ

១-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ របស់ដើមចោទឈ្មោះ [redacted] សុខនី ភេទស្រី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩២ ឃើញថាធ្វើឡើងត្រឹមត្រូវស្របតាមទម្រង់ដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ម៉្យាងវិញទៀតឃើញថា លំនៅឋានរបស់ភាគីមានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ នាំឲ្យសាលាដំបូងខេត្តតាកែវអាចយករឿងក្តីនេះមកដោះស្រាយបានស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២-ផ្អែកតាមសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ៖៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ៖ ០១/២០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានស្រុកសំរោង ខេត្តតាកែវ ឃើញថាប្តីឈ្មោះ [redacted] ស៊ីដេត កើតថ្ងៃ១២ ខែសីហា ឆ្នាំ១៩៩២ និងប្រពន្ធឈ្មោះ [redacted] សុខនី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩២ ។ តាមសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នេះ អាចឲ្យតុលាការជឿជាក់បានថាដើមចោទ និងចុងចម្លើយពិតជាមានទំនាក់ទំនងជាប្តីប្រពន្ធនឹងគ្នាស្របច្បាប់ពិតប្រាកដមែន ។

៣-ឃើញថា ដើមចោទឈ្មោះ [redacted] សុខនី បានប្តឹងលែងលះពីចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ដោយហេតុថា រស់នៅមិនចុះសម្រុងនឹងគ្នា និងបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលប្រហែលជាង ០១ឆ្នាំមកហើយ ដែលផ្ទុយទៅនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។ ដែលនេះជាមូលហេតុមួយស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចលែងលះភាគីទាំងពីរតាមការទាមទាររបស់ដើមចោទ ។

៤-ផ្អែកតាមការថ្លែងការណ៍របស់ភាគីទាំងសងខាង ក៏ដូចជាសេចក្តីចម្លងសំបុត្រកំណើតលេខ៖ ១២៩ នៃសៀវភៅកំណើតលេខ៖០៤/២០២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ សៀវភៅគ្រួសារលេខ ៖០០០១០៩ ស.រ និងសៀវភៅស្នាក់នៅលេខ៖ស.០០០៨៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ឃើញថាឈ្មោះ [redacted] សុខនីតា ភេទស្រី កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មានឪពុកឈ្មោះ [redacted] ស៊ីដេត និងម្តាយឈ្មោះ [redacted] សុខនី ។ ក្នុងករណីនេះ អាចឲ្យតុលាការជឿជាក់បានថាដើមចោទ និងចុងចម្លើយពិតជាមានកូនជាមួយគ្នាចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា ពិតប្រាកដមែន ។

៥-ឃើញថា ដើមចោទទាមទារសិទ្ធិអំណាចមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា ភេទស្រី កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។ ក្នុងករណីនេះ តុលាការយល់ឃើញថា សព្វថ្ងៃកូនស្រីខាងលើនេះ គឺស្ថិតក្រោមការចិញ្ចឹមបីបាច់ថែរក្សាដោយភាគីចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ស្រាប់ហើយដើមចោទបានចេញមករស់នៅបែកពីកូនចាប់តាំងពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ រហូតមកដល់បច្ចុប្បន្ននេះ ។ មួយវិញទៀតតាមការថ្លែងការណ៍របស់ចុងចម្លើយ ក៏ដូចជាពិនិត្យទៅលើឯកសារភស្តុតាងនានាដែលចុងចម្លើយដាក់ជូនតុលាការ ឃើញថា ចុងចម្លើយមានការងារជាមន្ត្រីរាជការ មានប្រាក់ខែច្បាស់លាស់ និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សារកូនបានល្អជាងការដែលកូនទៅរស់នៅជាមួយភាគីដើមចោទ ។ ហេតុដូច្នេះដើម្បីជាប្រយោជន៍ដល់កូន គប្បីតុលាការកំណត់យកភាគីចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] សុខនីតា ភេទស្រី កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ស្របតាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ។



Scanned with CamScanner

៦-ផ្អែកតាមការថ្លែងការណ៍របស់គាគីទាំងសងខាង ឃើញថាមានទ្រព្យសម្បត្តិរួមមួយចំនួន ប៉ុន្តែភាគីមិនបានដាក់ភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់នោះទេ ។ ហើយមួយវិញទៀតតុលាការយល់ឃើញថា តាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ក៏ប៉ុន្តែភាគីមិនបានធ្វើឡើងឲ្យបានត្រឹមត្រូវស្របតាមបញ្ញត្តិនៃមាត្រានេះទេ គ្រាន់តែអះអាងដោយមាត់ទទេតែប៉ុណ្ណោះ ។ ហើយចំពោះការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិរួម គឺភាគីទាំងសងខាងអាចដាក់ពាក្យស្នើសុំតាមក្រោយបាន ។ ហេតុដូច្នេះ គប្បីតុលាការមិនសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិរួមនេះទេ ។

៧-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ហេតុដូច្នេះសម្រេច**

១-ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] សុខនី ភេទស្រី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-លែងលះដើមចោទឈ្មោះ [redacted] សុខនី ពីចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ចាប់ពីពេលនេះតទៅ ។

៣-កំណត់យកចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនចំនួន ០១ នាក់ ឈ្មោះ [redacted] សុខនីតា ភេទស្រី កើតថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

-សាលក្រមនេះបានទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ ចំពោះមុខដើមចោទឈ្មោះ [redacted] សុខនី និងចុងចម្លើយឈ្មោះ [redacted] ស៊ីដេត ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។៚

ថ្ងៃសុក្រ ១១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

តាកែវ,ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃសុក្រ ១១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

តាកែវ,ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

តាកែវ,ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

**ចៅក្រម**

[redacted]



Scanned with CamScanner